**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**លេខ** : ០២២/២៦ **ក.ប**/ស.ជ.ណ.ទ.ជ.ម.ក

# សេចក្តីជូនដំណឹង
# ស្តីពី
# ឱកាសអភិវឌ្ឍជំនាញ និងការងារ
# សម្រាប់បងប្អូនអតីតពលករខ្មែរដែលបានវិលត្រឡប់ពីក្រៅប្រទេស

ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ មានកិត្តិយសសូមជូនដំណឹងដល់សាធារណជន និងបងប្អូនអតីតពលករខ្មែរដែលបានវិលត្រឡប់ពីក្រៅប្រទេសឱ្យបានជ្រាបថា ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ សហការជាមួយមជ្ឈមណ្ឌលពលករទេសន្តរប្រវេសន៍មាតុភូមិនិវត្តន៍កម្ពុជា (HRCC) រៀបចំកម្មវិធីបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈនិងសហគ្រិនភាព និងផ្តល់ការងារដោយឥតគិតថ្លៃដល់អតីតពលករខ្មែរ ដើម្បីផ្តល់ឱកាសអភិវឌ្ឍជំនាញបន្ថែម និងប្រើប្រាស់បទពិសោធន៍ការងារពីក្រៅប្រទេស ស្របទៅនឹងតម្រូវការទីផ្សារការងារក្នុងស្រុក និងចាប់ផ្តើមអាជីវកម្មដោយខ្លួនឯងប្រកបដោយជោគជ័យ។

ក្រសួងសូមអំពាវនាវដល់បងប្អូនអតីតពលករខ្មែរដែលបានវិលត្រឡប់ពីក្រៅប្រទេស មកចុះឈ្មោះចូលរៀនកម្មវិធីបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈនិងសហគ្រិនភាព ដោយឥតគិតថ្លៃ នៅមជ្ឈមណ្ឌលពលករទេសន្តរប្រវេសន៍មាតុភូមិនិវត្តន៍កម្ពុជា (HRCC) ដែលមានទីតាំងនៅក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ឬតាមរយៈទូរសព្ទលេខ +៨៥៥ ១២ ៦៤៦ ៥០០/+៨៥៥ ១០ ៦៤៦ ៥០០ នៅរៀងរាល់ម៉ោងធ្វើការ។ ចំពោះបងប្អូនអតីតពលករខ្មែរដែលចង់ស្វែងរកការងារ សូមទំនាក់ទំនងមកទីភ្នាក់ងារជាតិមុខរបរ និងការងារ (NEA) តាមរយៈប្រព័ន្ធ Hotline លេខ ១២៩៧។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមសាធារណជន និងបងប្អូនអតីតពលករខ្មែរដែលបានវិលត្រឡប់ពីក្រៅប្រទេស ជ្រាបជាព័ត៌មាន។

ថ្ងៃ ពុធ ១រោច ខែ ទុតិយាសាឍ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០២៦

**រដ្ឋមន្ត្រី**

**ហេង សួរ**

មជ្ឈមណ្ឌលពលករទេសន្តរ
ប្រវេសន៍មាតុភូមិនិវត្តន៍កម្ពុជា

ការងារខ្ញុំ

អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩